# ព្រះពុទ្ធសាសនានិងបញ្ហាប្រឈម

កម្ពុជាជាប្រទេសមួយដែលគោរពជឿលើព្រះពុទ្ធសាសនា ដែលមានប្រជាពលរដ្ឋប្រមាណជាជាង ៩០ភាគរយបានកាន់ព្រះពុទ្ធសាសនា ហើយព្រះពុទ្ធសាសនាត្រូវបានចាត់ទុកជាសាសនារបស់រដ្ឋ។ ប៉ុន្តែ បើយើងធ្វើការសង្កេតជាទូទៅ យើងឃើញថា ទន្ទឹមនឹងការមានសុខសន្តិភាពក្រោមការដឹកនាំដោយយក ចិត្តទុកដាក់ និងប្រកបទៅដោយគតិបណ្ឌិតដ៏ឈ្លាសវៃរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ជានាយករដ្ឋមន្ត្រី ក៏សង្គមមួយនេះនៅតែមានការកើតឡើងនូវបញ្ហាចាក់ស្រេះខ្លះៗដែលបណ្តាលមកពី ការស្រុតចុះនៃសីលធម៌សង្គមផងដែរ។ ទោះបីជាមានការយកចិត្តទុកដាក់ក្នុងការអប់រំតាមភូមិសិក្សា តាមវត្តអារាម តាមមូលដ្ឋានយ៉ាងណាក៏ដោយ ក៏អំពើហិង្សា ការប្លន់សម្លាប់ ការកេងប្រវ័ញ្ច អំពើពុករលួយ ការមិនគោរពសិទ្ធិមនុស្ស ការប្រមាថ ការជេរប្រទេច ការសេពគ្រឿងញៀន គ្រឿងស្រវឹង និងអំពើអសីល ធម៌នៅតែកើតមានជារឿយៗ ដែលនេះបញ្ជាក់ឱ្យឃើញថា ការគោរពជឿលើព្រះពុទ្ធសាសនាបាននឹង កំពុងតែជួបនឹងបញ្ហាប្រឈមផងដែរ ព្រោះការអប់រំនៅក្នុងព្រះពុទ្ធសាសនា ពុំបានណែនាំ អប់រំ ទូន្មាន ប្រៀនប្រដៅដល់ពុទ្ធសាសនិកឱ្យប្រព្រឹត្តិអំពើទាំងនោះឡើយ។

មានពិធីបុណ្យបែបព្រះពុទ្ធសាសនាជាច្រើនដែលតែងតែប្រារព្ធធ្វើជារៀងរាល់ឆ្នាំ មានដូចជា ពិធី បុណ្យមាឃបូជា ពិធីបុណ្យវិសាខបូជា និងពិធីភ្ជុំបិណ្ឌ ជាដើម ហើយក្រៅពីពិធីបុណ្យធំៗទាំងនេះ ប្រជា ពុទ្ធបរិស័ទខ្មែរតែងតែប្រារព្ធពិធីបុណ្យតាមបែបព្រះពុទ្ធសាសនាជាច្រើនទៀតនៅតាមផ្ទះសម្បែង និងទី វត្តអារាមនានា ដូចជាពិធីធ្វើបុណ្យដាក់ទាន ពិធីសូត្រមន្ត សង្ឃទាន បច្ច័យបួន កឋិនទាន និងការកាន់ ឧបោសថសីលជាដើម តែវាហាក់ដូចជាមិនទាន់ឆ្លើយតបទៅនឹងតម្លៃស្នូលនៃទស្សនវិជ្ជាជាសាកលរបស់ ព្រះពុទ្ធសាសនា ដែលស្ថិតនៅត្រង់ទស្សនវិជ្ជាបង្កប់ដោយអត្ថន័យអប់រំ សន្តិភាព អហិង្សា ការអត់ឱន និងការមិនបៀតបៀនគ្នា ដែលជាគោលការណ៍គោរពសិទ្ធិមនុស្សដែលពិភពលោកប្រាថ្នាចង់បាននៅឡើ យ។ បច្ចុប្បន្ន បុគ្គលដែលជាពុទ្ធសាសនិកមួយចំនួនហាក់ដូចជាមិនបានប្រកាន់ខ្ជាប់នូវគោលការណ៍នៃ ព្រះពុទ្ធសាសនាទេ ពោលគឺគេគោរពព្រះពុទ្ធសាសនាតែសម្បកក្រៅ ដោយបណ្តោយខ្លួនឱ្យធម៌ប្រមាថ និងអំពើអាក្រក់ជាអ្នកដឹកមុខទៅវិញ។ ជាក់ស្តែង អំពើហិង្សា ការសេពគ្រឿងញៀន គ្រឿងស្រវឹង ការ ឈ្លក់វក់វីនឹងអំណាច បុណ្យសក្តិ ទឹកប្រាក់ និងសម្ភារៈនិយមជាដើម កំពុងតែវាយលុកយ៉ាងពេញទំហឹង ទៅលើបុគ្គលមួយចំនួននោះ។ ក្នុងចំណោមប្រជាជនសរុបប្រមាណជា១៥លាននាក់ មានអ្នកកាន់ព្រះពុទ្ធ សាសនាដល់ទៅជាង៩០% ហើយនៅទូទាំងប្រទេសមានវត្តព្រះពុទ្ធសាសនាសរុបចំនួន ៤៨៧២(គណៈ មហានិកាយចំនួន៤ ៦៥៦វត្ត និងគណៈធម្មយុត្តិកនិកាយចំនួន ២១៦វត្ត) ដែលមានព្រះសង្ឃសរុប ចំនួន ៦៩ ១៩៩អង្គ និងមានពីរនិកាយធំគឺ មហានិកាយ មានព្រះសង្ឃសរុបចំនួន ៦៤ ៤០៧ អង្គ និង

ធម្មយុត្តិកនិកាយ មានព្រះសង្ឃសរុបចំនួន ៤ ៧២៤អង្គ។[១] ចំនួននេះអាចបង្ហាញបញ្ជាក់បានអំពីជំនឿដ៏មុតមាំរបស់ពលរដ្ឋខ្មែរទៅលើព្រះពុទ្ធសាសនា ហើយវាក៏ស័ក្តិសមណាស់ដែលប្រទេសនេះចាត់ទុកព្រះពុទ្ធសាសនាជាសាសនារបស់រដ្ឋ។ ប៉ុន្តែអ្វីដែលគួរឱ្យកត់សម្គាល់នោះ គឺទស្សនវិជ្ជាដ៏មានតម្លៃរបស់ព្រះពុទ្ធសាសនាដែលប្រៀបបាននឹងឱសថទិព្វ សម្រាប់ព្យាបាលជំងឺសង្គមនោះ មិនទាន់ត្រូវបានប្រើប្រាស់ឱ្យបានត្រឹមត្រូវដើម្បីលើកកម្ពស់សុខមាលភាពសង្គមនៅឡើយទេ។ មានមនុស្សវ័យចំណាស់មួយចំនួនដែលតាំងខ្លួនជាអ្នកគោរព និងជាអ្នកប្រតិបត្តិព្រះពុទ្ធសាសនា តែបែរជាប្រព្រឹត្តផ្ទុយពីគោលការណ៍សាសនា ខណៈដែលយុវវ័យជំនាន់ក្រោយមួយចំនួនបានចាត់ទុកព្រះពុទ្ធសាសនាថាហួសសម័យ ឬក៏ជាកិច្ចការរបស់មនុស្សចាស់តែប៉ុណ្ណោះ។

តាមពិតព្រះពុទ្ធសាសនាមានតម្លៃសម្រាប់មនុស្សគ្រប់វ័យ និងគ្រប់ស្រទាប់សង្គម ប៉ុន្តែអ្វីដែលនៅខ្វះចន្លោះនោះ គឺវិធីសាស្ត្រក្នុងការអប់រំ ការទាក់ទាញមនុស្សឱ្យចូលរួមតែប៉ុណ្ណោះ។ ជាក់ស្តែង សមាគមព្រះសង្ឃមួយចំនួនដែលបានអនុវត្តកម្មវិធីអប់រំតាមបែបព្រះពុទ្ធសាសនានៅតាមសាលារៀន និគមជនបទ ក៏បានទាក់ទាញយុវវ័យជាច្រើនឱ្យចូលរួមស្តាប់ព្រះធម៌អប់រំចិត្តផងដែរ។ ដូច្នេះ ទន្ទឹមនឹងការមើលឃើញឬស្តីបន្ទោសយុវវ័យថា មិនចាប់អារម្មណ៍និងឱ្យតម្លៃទៅលើព្រះពុទ្ធសាសនានោះ យើងក៏គួរចោទសួរដែរថា ហេតុអ្វីបានជាយុវជនទាំងនោះមិនចាប់អារម្មណ៍ និងឱ្យតម្លៃចំពោះព្រះពុទ្ធសាសនា? តើស្ថាប័នដែលពាក់ព័ន្ធ? និងបានធ្វើអ្វីខ្លះក្នុងន័យបញ្ជ្រាបការអប់រំទស្សនវិជ្ជាព្រះពុទ្ធសាសនាទៅដល់យុវជនស្រករក្រោយ?

បើយោងទៅតាមគម្ពីរព្រះពុទ្ធសាសនា ព្រះពុទ្ធបរមគ្រូទ្រង់បានឈ្វេងយល់រួចស្រេចទៅហើយថា សាសនារបស់ព្រះអង្គនឹងត្រូវផុតរលត់ត្រឹមរយៈពេល ៥ ០០០ព្រះវស្សា ហើយការផុតរលត់នៃព្រះពុទ្ធសាសនាមិនមែនបណ្តាលមកពីសាសនាដទៃណាមកបំផ្លាញនោះឡើយ គឺដោយសារតែអ្នកគោរពនិងប្រតិបត្តិព្រះពុទ្ធសាសនាខ្លួនឯងតែម្តង។ បើសិនជាយើងធ្វើការសង្កេតទៅលើបញ្ហានានាដែលកើតមានក្នុងសង្គមនាពេលបច្ចុប្បន្ន ក៏អាចទំនងជាភស្តុតាងដែលអាចបញ្ជាក់ពីបញ្ហានេះបានខ្លះដែរ។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ក៏ការពង្រឹងវិស័យព្រះពុទ្ធសាសនា គឺជាកិច្ចការដែលមិនអាចមើលរំលងបាននោះដែរ។ មានមានបុគ្គលមួយចំនួនបានចោទជាសំណួរថា *តើហេតុអ្វីបានជាប្រទេសកាន់ព្រះពុទ្ធសាសនាបែរជាមានអ្នកប្រើអំពើហិង្សា អំពើឆក់ប្លន់ និងអំពើអបាយមុខផ្សេងៗទៅវិញ?* គឺប្រហែលជាមកពីអ្នកកាន់ព្រះពុទ្ធសាសនា និងស្ថាប័នពាក់ព័ន្ធមិនទាន់បានផ្តល់តម្លៃគ្រប់គ្រាន់ដល់ព្រះពុទ្ធសាសនាដែលជាសាសនារបស់រដ្ឋនៅឡើយ។ ដូច្នេះ ការតម្រង់ទិសសង្គម យើងគួរទាញយកឱសថទិព្វនៃព្រះពុទ្ធ

---

[១] យោងតាមនាយកដ្ឋានកិច្ចការព្រះពុទ្ធសាសនា នៃក្រសួងធម្មការ និងសាសនា ដែលបានផ្តល់ស្ថិតិតួលេខនេះ គឺគិតត្រឹមថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៦។

សាសនាមកប្រើប្រាស់ ដើម្បីព្យាបាលជំងឺសង្គម ជាពិសេសដើម្បីបន្សាបមេរោគហិង្សា ការសេពគ្រឿងញៀន គ្រឿងស្រវឹង ការឈ្លក់វក់នឹងអំណាច បុណ្យសក្តិ ទឹកប្រាក់ សម្ភារៈនិយម និងការប្រមាថចេញពីមនុស្សខ្មែរមួយចំនួននោះ។ ប្រសិនបើមេរោគទាំងនោះ អាចព្យាបាលបានមែន សង្គមខ្មែរនឹងស្គាល់តម្លៃសីលធម៌ឡើងវិញ ហើយប្រទេសជាតិនឹងស្គាល់សុខសន្តិភាព និងការគោរពសិទ្ធិមនុស្សយ៉ាងពេញលេញជាក់ជាមិនខាន។ ឱសថទិព្វនោះអាចមានប្រសិទ្ធភាពទៅបាន គឺទាល់តែមានការចូលរួមពីមន្ត្រីសង្ឃជាន់ខ្ពស់ មន្ត្រីសង្ឃ ពុទ្ធបរិស័ទ ស្ថាបនពាក់ព័ន្ធ និងអ្នកស្រាវជ្រាវចូលរួមយ៉ាងសស្រាក់ស្រាំ និងត្រូវនាំគ្នាធ្វើការពិភាក្សាលើការងារពង្រឹងព្រះពុទ្ធសាសនា ទាំងវិន័យសង្ឃ និងទាំងការបដិបត្តិ ដើម្បីរកឱ្យឃើញនូវបញ្ហាប្រឈម និងដំណោះស្រាយនានា។ ត្រូវរៀបចំឱ្យបាននូវផែនការយុទ្ធសាស្ត្រសម្រាប់អភិវឌ្ឍន៍ ដើម្បីរម្ងាប់អធិករ ដែលជាបាតុភូតអវិជ្ជមាននានា ដែលកើតមាននៅក្នុងវិស័យព្រះពុទ្ធសាសនានៃសង្គមកម្ពុជា និងធ្វើយ៉ាងណាឱ្យក្លាយទៅជាប្រយោជន៍សម្រាប់ពុទ្ធបរិស័ទ ដើម្បីទ្រទ្រង់ព្រះពុទ្ធសាសនា ដែលជាប្រទីបបំភ្លឺផ្លូវសង្គមកម្ពុជាឱ្យមានការអភិវឌ្ឍប្រកបដោយវឌ្ឍនធម៌ សុភមង្គល និងសេចក្តីរុងរឿង។

បច្ចុប្បន្នមានព្រះសង្ឃ និងបុគ្គលមួយចំនួន បានធ្វើឱ្យប៉ះពាល់ដល់ភាពស្អាតស្អំរបស់ព្រះពុទ្ធសាសនាដែលជាសាសនារបស់រដ្ឋ ដូច្នេះដើម្បីថែរក្សាព្រះពុទ្ធសាសនាឱ្យបានគង់វង្ស មន្ត្រីសង្ឃ និងរាល់ស្ថាប័នពាក់ព័ន្ធ ក៏ដូចជាពុទ្ធបរិស័ទទាំងអស់ត្រូវសហការគ្នា ធ្វើយ៉ាងណាឱ្យព្រះសង្ឃគួរទទួលបាននូវការអប់រំដែលមានគុណភាព និងមានការគោរពវិន័យយ៉ាងតឹងរ៉ឹង ទើបអាចសាងភាពល្អស្អាតរបស់ព្រះពុទ្ធសាសនាបាន ហើយមានតែការអប់រំដែលមានគុណភាព ប្រកបដោយវិន័យតឹងរ៉ឹង និងមានការដាក់ទណ្ឌកម្មចំពោះការប្រព្រឹត្តិខុសឆ្គងរបស់ព្រះសង្ឃ ក៏ដូចជាអ្នកប្រតិបត្តិសាសនានៅតាមវត្តអារាមតែប៉ុណ្ណោះ ដែលអាចធ្វើឱ្យវិស័យព្រះពុទ្ធសាសនាថ្កុំថ្កើងឡើង ពោលគឺយើងត្រូវអនុវត្តជាការចាំបាច់ ដើម្បីធានាថា ព្រះសង្ឃបានប្រណិប័តន៍ត្រឹមត្រូវតាមក្រឹត្យក្រមនៃព្រះពុទ្ធសាសនា។ នាពេលកន្លងមក ព្រះសង្ឃនិងបុគ្គលមួយចំនួនតូចដែលស្លៀកស្បង់ចីពរបានប្រព្រឹត្តអំពើល្មើសច្បាប់ និងអសីលធម៌ ដែលមានជាអាទិ៍ដូចជា ការលេងល្បែងស៊ីសង ការប្រព្រឹត្តអំពើអនាចារ ការប្រើប្រាស់គ្រឿងញៀន ការប្រើប្រាស់គ្រឿងស្រវឹង និងការប្រើប្រាស់អាវុធខុសច្បាប់ជាដើម ដែលសកម្មភាពទាំងនេះបានធ្វើឱ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ភាពស្អាតស្អំរបស់ព្រះពុទ្ធសាសនានៅកម្ពុជា។ ឧទាហរណ៍ដូចជា ករណីមួយដែលបានធ្វើឱ្យមានការភ្ញាក់ផ្អើលពេញផ្ទៃប្រទេសកាលពីឆ្នាំ២០១០ គឺមានអតីតសង្ឃ **នេត ខៃ** ក្នុងវត្តស្រះចក សង្កាត់ស្រះចក មានរឿងអាស្រូវដ៏លេចធ្លោមួយក្នុងទីក្រុងភ្នំពេញ បានកើតឡើងដោយសារតែអតីតសង្ឃអង្គនេះបានធ្វើការថតរូបវីដេអូនៃស្ត្រីជាច្រើននាក់ ខណៈពេលដែលស្ត្រីទាំងនោះកំពុងងូតទឹកមន្តដោយអាក្រាតកាយ។ អតីតសង្ឃ **នេត ខៃ** ត្រូវបានអាជ្ញាធរចាប់ខ្លួន និងត្រូវបានតុលាការសម្រេចកាត់ទោសឱ្យជាប់ពន្ធនាគាររយៈពេល២០ឆ្នាំ ចំពោះបទចោទ ផលិត និងចែកចាយរូបភាពអាសអាភាស។ ករណីមួយទៀតដែលព្រះចៅអធិការវត្ត និងព្រះសង្ឃបួនអង្គនៅក្នុងវត្តមួយក្នុងខេត្តកំពង់ស្ពឺ ត្រូវចាប់ខ្លួននិងបញ្ជូនទៅ

តុលាការ ក្រោយពីពួកគេប្រើប្រាស់ថ្នាំញៀន។ ករណីមួយផ្សេងទៀត ព្រះចៅអធិការវត្តកំពង់ក្តុល ធ្វើឱ្យខូចដល់តម្លៃរបស់ព្រះសង្ឃ នៅក្នុងព្រះពុទ្ធសាសនា ដែលលបលួចទាក់ទងជាមួយស្ត្រីម្នាក់រហូតក្លែងខ្លួនជាគ្រហស្ថ និមន្តចេញពីកុដិទៅសឹងនៅក្នុងផ្ទះស្រីស្នេហ៍ ក៏ត្រូវប្រជាពលរដ្ឋឃាត់ខ្លួនឱ្យនគរបាលខណ្ឌដង្កោ កាលពីវេលាម៉ោង២ និង៣០នាទីរំលងអធ្រាត្រ ឈានចូលថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៨ នៅក្នុងភូមិខ្វិត សង្កាត់សាក់សំពៅ ខណ្ឌដង្កោ។ ករណីដែលភិក្ខុ១អង្គបានក្លាយជាជនល្មើសយ៉ាងសាហាវ ដោយបានយកដែកឆាបចាក់នារីម្នាក់ បណ្តាលឱ្យរងរបួសធ្ងន់ ក្រោយពេលណាត់ជួបគ្នា នៅទំនប់អូរខែជនស្ថិតក្នុងភូមិអណ្តូងថ្មមាស សង្កាត់និមិត្ត ក្រុងប៉ោយប៉ែត ដែលហេតុការណ៍ស្ទើរតែមិនអាចជឿនេះ បានបង្កការភ្ញាក់ផ្អើលកាលពីវេលាម៉ោង៨ និង៣០នាទីព្រឹក ថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០១៨កន្លងទៅ។ យ៉ាងណាក៏ដោយ ភិក្ខុអង្គនេះត្រូវបានព្រះអនុគណក្រុង និងប្រធានការិយាល័យធម្មការ និងសាសនាក្រុងប៉ោយប៉ែត ផ្សឹកនៅព្រឹកថ្ងៃដដែលនោះ នៅវត្តនិមិត្តសុទ្ធារាម ក្នុងសង្កាត់និមិត្ត រួចប្រគល់ឱ្យសមត្ថកិច្ចចាត់ការបន្តតាមផ្លូវច្បាប់[២] និងមានករណីផ្សេងៗជាច្រើនទៀត។

ការលើកឧទាហរណ៍ខាងលើ គឺបានបង្ហាញពីការចាត់វិធានការចំពោះអតីតសង្ឃមួយចំនួនដែលបានប្រព្រឹត្តិខុសឆ្គងនឹងវិន័យសង្ឃនៃគន្លងព្រះពុទ្ធសាសនា ដែលនេះបង្ហាញអំពីការចាត់វិធានការតាមរយៈមហាសន្និបាតមន្ត្រីសង្ឃទូទាំងប្រទេស លើកទី២៥ ក្នុងរាជធានីភ្នំពេញ កាលពីថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៧ ដែលមន្ត្រីសង្ឃប្តេជ្ញានឹងចាត់វិធានការតឹងរឹងចំពោះព្រះសង្ឃណាដែលប្រព្រឹត្តខុស ហើយវិធានការទាំងនោះមានដូចជា ការពិន័យទូន្មានចំពោះការប្រព្រឹត្តខុសឆ្គងកម្រិតស្រាល ការចាប់ផ្សឹក និងបញ្ជូនឱ្យអាជ្ញាធរដោះស្រាយតាមផ្លូវច្បាប់ចំពោះការប្រព្រឹត្តខុសធ្ងន់ធ្ងរជាដើម។

ម្យ៉ាងវិញទៀតនៅក្នុងឱកាសមហាសន្និបាតមន្ត្រីសង្ឃទូទាំងប្រទេស លើកទី២៥នោះដែរ ក៏បានផ្តល់វេទិកាដល់ព្រះសង្ឃចូលរួមបានបញ្ចេញមតិយោបល់ផងដែរ ហើយនាពេលនោះ ព្រះសង្ឃមួយអង្គបានមានសង្ឃដីកាថា ក្នុងរយៈពេល១០ឆ្នាំដែលព្រះអង្គគង់នៅក្នុងវត្តអារាម ព្រះអង្គពុំឃើញមានព្រះសង្ឃប្រព្រឹត្តអ្វីខុសធ្ងន់ធ្ងរនៅឡើយទេ។ ក៏ប៉ុន្តែ ព្រះអង្គបានមានសង្ឃដីកាដោយសុំមិនបញ្ចេញឈ្មោះថា *បើព្រះសង្ឃអង្គណាធ្វើខុសធ្ងន់ធ្ងរ ព្រះសង្ឃនោះ នឹងត្រូវចាប់ផ្សឹក និងបញ្ជូនទៅអាជ្ញាធរមានសមត្ថកិច្ច*។ រីឯព្រះតេជគុណ **វន វង្ស** ជាចៅអធិការវត្តមួយរូបមកពីស្រុកសូទ្រនិគម ខេត្តសៀមរាប បានថ្លែងថា *កង្វះការអប់រំ គឺជាមូលហេតុដែលធ្វើឱ្យព្រះសង្ឃមួយចំនួនជ្រុលខ្លួនប្រព្រឹត្តខុស*។ ព្រះតេជគុណមានសង្ឃដីកាបន្តទៀតថា *ស្ថាប័នអប់រំខាងពុទ្ធសាសនានៅកម្ពុជាមិនទាន់មានចំនួនស្ថាប័នសិក្សាគ្រប់គ្រាន់នឹងចំនួនព្រះសង្ឃដែលបន្តកើនឡើងនៅឡើយទេ។ ដើម្បីឱ្យគ្រប់គ្រាន់ លុះត្រាតែ ស្ថាប័នពុទ្ធសាសនាឯករាជ្យ*

[២] កោះសន្តិភាព ចេញផ្សាយថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០១៨។

*ហើយមានវិសាលភាពផ្សព្វផ្សាយធម៌វិន័យឱ្យស៊ីជម្រៅទៅក្នុងខួរក្បាល ឬទស្សនៈរបស់ខ្មែរ ហើយបង្កើតសាលាបាលី ដែលសង្ឃចូលមករៀនឱ្យចេះដឹង។ ព្រះអង្គមានសង្ឃដីកាបន្ថែមថា បុគ្គលដែលចង់បួសជាព្រះសង្ឃ គួរតែតម្រូវឱ្យស្នាក់នៅ និងរៀនសូត្រនៅវត្តរយៈពេលយ៉ាងហោចណាស់មួយឆ្នាំ ដើម្បីបញ្ជាក់ថាបុគ្គលនោះអាចគោរពតាមវិន័យព្រះសង្ឃបានត្រឹមត្រូវមុនពេលបុគ្គលនោះបួសជាព្រះសង្ឃ។*

ដូច្នេះវត្តអារាមនីមួយៗ គួរតែមានចំណាត់ការតឹងរ៉ឹង និងមានវិន័យច្បាស់លាស់ដើម្បីកុំឱ្យបុគ្គលឆ្លៀតឱកាសមួយចំនួនប្រើប្រាស់អត្តសញ្ញាណជាព្រះសង្ឃបំផ្លាញភាពស្អាតស្អំរបស់ពុទ្ធសាសនា ហើយកម្ពុជាត្រូវបង្កើនទាំងបរិមាណ និងពង្រឹងគុណភាពរបស់ព្រះសង្ឃ ជាពិសេសគឺបង្កើនស្ថាប័នអប់រំ និងពង្រឹងគុណភាពអប់រំអំពីព្រះពុទ្ធសាសនា ហើយពាក្យដែលថា ***ត្រីមួយកន្ត្រក ស្អុយមួយ គឺស្អុយទាំងអស់*** ក៏គួរតែឈប់ប្រើផងដែរ ព្រោះព្រះសង្ឃភាគច្រើនបានអនុវត្តត្រឹមត្រូវតាមក្បួនវិន័យរបស់ព្រះសង្ឃហើយ ហើយរដ្ឋាភិបាលក៏កំពុងតែរឹតបណ្តឹង និងឃ្លាំមើលឱ្យកាន់តែជិតដល់ចំពោះព្រះសង្ឃបន្ថែមទៀត ដើម្បីកសាងទំនុកចិត្តរបស់ពុទ្ធបរិស័ទខ្មែរចំពោះព្រះពុទ្ធសាសនា ដែលជាសាសនារបស់រដ្ឋ។

សរុបសេចក្តីមក បញ្ហាប្រឈមដែលកើតមាននៅក្នុងវិស័យព្រះពុទ្ធសាសនានោះ គឺយើងទាំងអស់គ្នា ត្រូវរួមគ្នាដោះស្រាយទាំងមន្ត្រីសង្ឃ ទាំងស្ថាប័នពាក់ព័ន្ធ ទាំងពុទ្ធបរិស័ទ ដើម្បីលើកកម្ពស់វិស័យព្រះពុទ្ធសាសនាឱ្យថ្កុំថ្កើងរុងរឿង សក្តិសមនឹងសាសនាមួយដែលមានប្រជាជនកម្ពុជាភាគច្រើនកាន់និងគោរពជឿ ក៏ដូចជាការរក្សាតម្លៃព្រះពុទ្ធសាសនាដែលជាសាសនាដ៏ឧត្តុងឧត្តម និងជាដួងព្រលឹងរបស់ពលរដ្ឋខ្មែរដែលបង្កប់នូវការអប់រំប្រៀនប្រដៅ និងទ្រឹស្តីព្រះពុទ្ធសាសនាតាមលក្ខណៈវិទ្យាសាស្ត្រដែលមនុស្សអាចទទួលយកបាន ហើយជាពិសេសគឺឱ្យសក្តិសមនឹងរដ្ឋធម្មនុញ្ញដែបានបានចែងយ៉ាងច្បាស់ថាព្រះពុទ្ធសាសនាជាសាសនារបស់រដ្ឋ ព្រះសង្ឃជាសាវ:របស់ព្រះពុទ្ធ ដែលមានព្រះត្រៃបិដកជាក្បួនខ្នាតដែលអាចជាប្រយោជន៍ចំពោះសង្គមកម្ពុជា ដែលជាការនាំមកនូវសន្តិភាព ការអភិវឌ្ឍធនធានមនុស្ស ការចូលរួមប្រកបដោយនិរន្តរភាព ជាប្រយោជន៍និងជារូបភាពក្នុងការទាក់ទាញអារម្មណ៍អ្នកដឹកនាំ ដោយការយកព្រះពុទ្ធសាសនា មករួមជាវិភាគទានក្នុងការគ្រប់គ្រងប្រទេសក្រោមបាវចនាគឺ ជាតិ សាសនា ព្រះមហាក្សត្រ៕